មជ្ឈមណ្ឌលឯកសារកម្ពុជា

# អៀង ធីរិទ្ធ ពិតជាមានបញ្ហាផ្នែកសតិបញ្ញាមែនទឺ?

*លឹម ជ័យទត្ត*

*កាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាត់តាំងអ្នកជំនាញមួយរូប គឺលោកសាស្ត្រាចារ្យ ចន ខាំប៊ែល ដែលមានជំនាញខាងមនុស្សចាស់ឲ្យធ្វើការវាយតម្លៃទៅលើស្ថានភាពកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នួន ជា និង អៀង សារី ។ នៅខែ មិថុនា ឆ្នាំ ២០១១ លោក ខាំប៊ែល បានចេញរបាយការណ៍ស្តីពីស្ថានភាពរបស់ជនជាប់ចោទទាំងបីរូបខាងលើ ។ លទ្ធផលនៅក្នុងរបាយការណ៍នោះបានបង្ហាញថា ជនជាប់ចោទ អៀង សារី និង នួន ជា មានសមត្ថភាពខាងកាយសម្បទា និងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងសវនាការ ។ ចំពោះស្ថានភាសុខភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អ្នកជំនាញរូបនេះបានធ្វើការសន្និដ្ឋានថា ជនជាប់ចោទ អៀង ធីរិទ្ធ មានបញ្ហាខាងស្មារតី និងប្រព័ន្ធសរសៃប្រសាទ ដែលរារាំងលទ្ធភាពក្នុងការចូលរួមពេញលេញក្នុងការជំនុំជម្រះ និងរារាំងដល់ការអនុវត្តសិទ្ធិក្នុងការចូលរួមការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ ។ បន្ថែមលើនេះ លោកសាស្ត្រាចារ្យ ខាំប៊ែល ក៏បានផ្តល់អនុសាសន៍ឲ្យមានការកែប្រែរបបថ្នាំរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និងស្នើឲ្យមានការតែងតាំងអ្នកជំនាញផ្នែកវិកលចរិត ដើម្បីធ្វើការវាយតម្លៃបន្ថែមទៅលើស្ថានភាពសតិបញ្ញារបស់ជនជាប់ចោទរូបនេះ ។*

*នៅក្នុងសវនាការទាក់ទងនឹងការសួរដេញដោលទៅលើអ្នកជំនាញស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទ កាលពីថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ លោក ចន ខាំប៊ែល បានឆ្លើយតបទៅនឹងសំណួរជាច្រើនរបស់ភាគីទាំងអស់នៅក្នុងសវនាការ រួមមានទាំងសំណួររបស់ចៅក្រមផង ដែលបានសួរពីស្ថានភាពកាយសម្បទា និងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ លោក ខាំប៊ែល បានសន្និដ្ឋានថា អៀង ធីរិទ្ធ កំពុងមានបញ្ហាជំងឺធ្ងន់ធ្ងរ អាចបាត់បង់ស្មារតីដោយសារ ថ្នាំដែលគាត់ប្រើប្រាស់សព្វថ្ងៃ និងបរិស្ថានសង្គមដែលគាត់កំពុងរស់នៅ ។ ជំងឺនេះអាចវិវឌ្ឍន៍ទៅដល់ការចុះខ្សោយសមត្ថភាពផ្នែកបញ្ញា និងអាចឈានទៅដល់ការបាត់បង់ការចងចាំ ។*

ការសន្និដ្ឋានរបស់លោកសាស្ត្រាចារ្យ ខាំប៉ែល គឺកើតចេញពីលទ្ធផលនៃការវាយតម្លៃតាមរយៈវិធីសាស្ត្រជាច្រើន ដែលលោកបានប្រើប្រាស់ក្នុងការធ្វើពិសោធសមត្ថភាពកាយសម្បទា និងបញ្ហាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ។ វិធីសាស្ត្រទាំងនោះរួមមាន ការពិនិត្យវាយតម្លៃទៅលើរបាយការណ៍របស់វេជ្ជបណ្ឌិតជំនាញនានា ដែលបានធ្លាប់បានពិនិត្យ និងព្យាបាលទៅលើជនជាប់ចោទ អៀង ធីរិទ្ធ ។ ការពិនិត្យឆ្លុះមើលខួរក្បាល ការធ្វើពិសោធឈាម ជួបជាមួយជនជាប់ចោទ អៀង ធីរិទ្ធ ដោយផ្ទាល់ និងពិនិត្យមើលទៅលើបំលាស់ទី និងអាកប្បកិរិយារបស់ជនជាប់ចោទ ។ លោក ខាំប៉ែល បានព្យាយាមធ្វើពិសោធន៍ការចងចាំរបស់ជនជាប់ចោទ អៀង ធីរិទ្ធ តាមរយៈវិធីសាស្ត្រពិនិត្យមើលទៅលើការស៊ីចង្វាក់គ្នារវាងលេខនៅក្នុងនាឡិកា និងតួអក្សរ ។ មិនត្រឹមតែប៉ុណ្ណោះ លោក ខាំប៉ែល បានធ្វើការអង្កេតតាមរយៈការសួរមនុស្សមួយចំនួនដែលនៅក្បែរ អៀង ធីរិទ្ធ ដោយសារបុគ្គលទាំងអស់នោះអាចមើលឃើញពីសកម្មភាពប្រចាំថ្ងៃរបស់ជនជាប់ចោទ ។ តាមរយៈការធ្វើពិសោធទៅលើសមត្ថភាពចងចាំរបស់ជនជាប់ចោទ អៀង ធីរិទ្ធ នេះ លោក ខាំប៉ែល បានរកឃើញថា អៀង ធីរិទ្ធ នៅតែមានបញ្ហាខាងការចងចាំដដែល ដោយសារជនជាប់ចោទមិនបានចាំថាខ្លួនធ្លាប់ធ្វើជាអតីតរដ្ឋមន្ត្រី សូម្បីឈ្មោះប្តី និងកូនរបស់ខ្លួនមានប៉ុន្មាននាក់ក៏មិនអាចចងចាំបានដែរ ។ ការសន្និដ្ឋានបែបនេះរបស់លោក ខាំប៉ែល បាននាំឲ្យមានការព្រួយបារម្ភជាទូទៅមួយទាក់ទងទៅនឹងការធ្វើពុតរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដើម្បីរួចផុតពីការកាត់ទោសរបស់តុលាការ ។ ដោយសារនៅក្នុងច្បាប់ជាតិក្តី និងច្បាប់អន្តរជាតិក្តី មិនអនុញ្ញាតឲ្យមានការជំនុំជម្រះទោសទៅលើជនដែលមិនមានបញ្ហាស្មារតីគ្រប់គ្រាន់ក្នុងការតតាំងនៅក្នុងសវនាការឡើយ ។ លោក ខាំប៉ែល បានអះអាងថា លោកក៏មានការព្រួយបារម្ភពីបញ្ហានេះ ដោយលោកបានធ្វើការសង្កេតយ៉ាងដិតដល់ ប៉ុន្តែមិនមានសញ្ញាណាមួយដែលបញ្ជាក់ថាជនជាប់ចោទ អៀង ធីរិទ្ធ ព្យាយាមធ្វើការបញ្ឆោត ឬធ្វើពុតជាមួយនឹងលោកឡើយ ។ សកម្មភាពរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលបានងើបពីកៅអី ហើយដើរចេញក្រៅបន្ទប់សវនាការដោយមិនមានការអនុញ្ញាតពីចៅក្រម ដោយស្ថិតក្នុងស្ថានភាពដូចជាមនុស្សដែលវង្វេងស្មារតីនៅអំឡុងពេលដែលនីតិវិធីកំពុងតែដំណើរការនោះ បានបង្ហាញថា ស្ថានភាពសតិបញ្ញាស្មារតីរបស់ជនជាប់ចោទកំពុងតែស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ ។ សាធារណជនភាគច្រើនដែលបានអង្គុយតាមដានសកម្មភាពនៅក្នុងសាលសវនាការ ហាក់បីដូចជាគិតថា វាគ្រាន់តែជាការប៉ុនប៉ងរបស់ អៀង ធីរិទ្ធ ក្នុងការធ្វើដូច្នេះ ដើម្បីឲ្យសាធារណជនឃើញថា ស្ថានភាពបញ្ហាស្មារតីរបស់ខ្លួនកំពុងតែធ្លាក់ដុនដាបប៉ុណ្ណោះ ពីព្រោះនៅមុនពេលដែល អៀង ធីរិទ្ធ ដើរចេញពីក្នុងបន្ទប់សវនាការ សាធារណជនឃើញជនជាប់ចោទអង្គុយនិយាយលេងសើចទៅកាន់សហមេធាវីការពារក្តីរបស់ខ្លួន បីដូចជាមិនមានអ្វីខុសប្លែកពីធម្មតាឡើយ ។

ប្តីត្បិតតែប្រវត្តិក្រុមគ្រួសាររបស់ជនជាប់ចោទ អៀង ធីរិទ្ធ ធ្លាប់មានម្តាយ និងបងស្រីឈ្មោះ ខៀវ ប៉ុណ្ណារី ដែលសាធារណជនស្គាល់ថាជាភរិយារបស់ ប៉ុល ពត កើតមានជំងឺបាត់បង់ផ្នែកបញ្ញាស្មារតីនេះក៏ដោយ ក៏លោកសាស្ត្រាចារ្យ ខាំប៉ែល បានបញ្ជាក់យ៉ាងច្បាស់ថា ជំងឺនេះមិនមែនជាជំងឺតពូជឡើយ ។ ជំងឺនេះ វាកើតឡើងតែចំពោះមនុស្សដែលចាប់ផ្តើមឈានចូលដល់វ័យចំណាស់ ហើយចំនួន ២០ភាគរយ នៃមនុស្សចាស់ដែលមានអាយុលើសពី៨០ឆ្នាំ បានកើតជំងឺនេះ ។ ជំងឺចុះខ្សោយផ្នែកបញ្ញាស្មារតីនេះ គឺបណ្តាលមកពីការស្លាប់បាត់បង់នៃកោសិកាខួរក្បាល ដែលបណ្តាលឲ្យអ្នកជំងឺចាប់ផ្តើមមានការចុះខ្សោយផ្នែកការចងចាំ វង្វេងវង្វាន់ស្មារតី នឹងអាចឈានទៅដល់ការបាត់បង់ការចងចាំតែម្តងនៅពេលអនាគត ។

គ្មាននរណាម្នាក់អាចដឹងច្បាស់ពីស្ថានភាពផ្នែកកាយសម្បទា ឬផ្នែកបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ឡើយ ។ លុះត្រាតែមានការពិនិត្យវាយតម្លៃពីវេជ្ជបណ្ឌិត ឬអ្នកជំនាញជាមុនសិន ។ ចំពោះការសម្រេចថា ជនជាប់មានសម្តភាពផ្នែកកាយសម្បទា ឬបញ្ញាស្មារតីក្នុងការចូលរួមក្នុងសវនាការ បាន ឬ មិនបាន គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនឹងធ្វើការសម្រេច ដោយផ្អែកទៅលើរបាយការណ៍និងការវាយតម្លៃយ៉ាងម៉ត់ចត់របស់អ្នកជំនាញទាំងអស់នោះ ។